# វិសាខបូជានិងសិល្បៈគំនូរតាមវត្តៈ ប្រសូត ត្រាស់ដឹង បរិនិព្វាន

វិសាខបូជា គឺជាបុណ្យមួយដ៏សំខាន់បំផុត ដែលប្រទេសអ្នកកាន់ព្រះពុទ្ធសាសនា និងពុទ្ធបរិស័ទទូទាំងពិភពលោក ក៏ដូចជាកម្ពុជាតែងប្រារព្ធធ្វើជារៀងរាល់ឆ្នាំ ដើម្បីរំលឹកនឹកដល់អភិលក្ខិតសម័យទាំងបី គឺថ្ងៃព្រះពុទ្ធទ្រង់ប្រសូត ត្រាស់ដឹង និងបរិនិព្វាន នាថ្ងៃ ១៥កើត ពេញបូណ៌មី ក្នុងខែពិសាខ។ ទន្ទឹមនឹងនេះ បុណ្យវិសាខបូជាត្រូវបានអង្គការសហប្រជាជាតិប្រកាសទទួលស្គាល់នៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៩៩ ហើយបានប្រារព្ធធ្វើនៅការិយាល័យអង្គការសហប្រជាជាតិជារៀងរាល់ឆ្នាំ (រូបលេខ១)។[1] ក្នុងប្រទេសកម្ពុជា វិសាខបូជាត្រូវបានរាជរដ្ឋាភិបាល កំណត់ជាថ្ងៃបុណ្យជាតិប្រចាំឆ្នាំ នៅក្នុងប្រតិទិនឈប់សម្រាកការងាររបស់មន្ត្រីរាជការ និយោជិត និងកម្មករ។




រូបលេខ១ វិសាខបូជាប្រារព្ធធ្វើនៅទីស្នាក់ការកណ្តាលអង្គការសហប្រជាជាតិ (រូបថតៈ www.undv.org)

នៅកម្ពុជា ជាទូទៅរាជរដ្ឋាភិបាលតែងរៀបចំប្រារព្ធធ្វើបុណ្យវិសាខបូជា នៅចំថ្ងៃ ១៥កើតខែពិសាខ នៅបរិវេណព្រះសក្យមុនីចេតិយកណ្តាលរាជធានីភ្នំពេញ ត្រង់មុខស្ថានីយរាជអយស្ម័យយាន ឃើញតាំងពីក្នុងរាជ្យព្រះបាទបរមរតនកោដ្ឋ[2] រហូតលុះសាង

[1] មហាសន្និបាតអង្គការសហប្រជាជាតិ បានអនុម័តតាមសេចក្តីសម្រេចលេខ 54/115 ក្នុងសម័យប្រជុំលើកទី៥៤ នាថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៩៩។

[2] ចង់ វង់, ១៩៦២, ទំ.៥៩២-៥៩៨

អត្ថបទដោយៈ ហៀន សុវណ្ណមរកត

បានព្រះសក្យមុនីចេតិយថ្មីលើភ្នំព្រះរាជទ្រព្យ តែងមានការនិមន្តចូលរួមពីព្រះសង្ឃគ្រប់ជាន់ថ្នាក់ និងមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំជាតិ និងមន្ត្រីរាជការ ប្រារព្ធបុណ្យវិសាខបូជាយ៉ាងអធិកអធមក្រៃលែង (រូបលេខ២)។ ដោយឡែកនៅតាមបណ្ដាវត្តអារាមនានាទូទាំងប្រទេស ក៏តែបានរៀបចំពិធីបុណ្យវិសាខបូជាព្រមៗគ្នា ស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលបានចែងថាព្រះពុទ្ធសាសានាជាសាសនារបស់រដ្ឋ។



*រូបលេខ២ **សម្ដេចវិបុលសេនាភក្ដី សាយ ឈុំ** អញ្ជើញជាអធិបតីភាពដ៏ខ្ពង់ខ្ពស់ក្នុងពិធីបុណ្យពិសាខបូជា នៅបរិវេណព្រះមហាសក្យមុនីចេតិយភ្នំព្រះរាជទ្រព្យ ឆ្នាំ២០១៩ (រូបថត៖ AMS Central)*

ជាការពិត ក្នុងគម្ពីរបឋមសម្ពោធិបានចែងសម្ដែងថា បុរាណាចារ្យលោកតាក់តែងបុណ្យវិសាខបូជា ដើម្បីរំលឹកដល់អភិមង្គលនៃថ្ងៃព្រះអង្គទ្រង់ប្រសូត ទ្រង់ត្រាស់ដឹង និងទ្រង់បរិនិព្វាន។ នក្ខត្តសម័យទាំងបីដូចពោលខាងលើ ត្រូវគ្នាគ្រប់ប្រការ ចំនៅថ្ងៃ១៥កើតពេញបូរមី ខែពិសាខទាំងអស់ ដោយខុសតែឆ្នាំ។[3] មិនតែប៉ុណ្ណោះ បើរាប់ពីថ្ងៃ១៥កើតពេញបូរមី ខែមាឃ ដល់ថ្ងៃ១៥កើត ពេញបូរមី ខែពិសាខ គឺរយៈពេលបីខែគត់ ដូចព្រះ

[3] *សូមអាន៖ គម្ពីរបឋមសម្ពោធិ ចុះលេខបញ្ជីសារពើភណ្ឌ FEMC 37-40 (ទួលជុំ)។*

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ពុទ្ធអង្គបានប្រកាសចំពោះភិក្ខុទាំង១២៥០អង្គ ក្នុងចតុរង្គសន្និបាត ថាព្រះអង្គនឹងរំលត់ខន្ធចូលកាន់បរមនិព្វានក្នុងបីខែទៀត។

យោងតាមឯកសារព្រះរាជពិធីទ្វាទសមាសបញ្ជាក់ដូចគ្នាថា វិសាខបូជា គឺជាមហាមង្គលរបស់ព្រះសម្មាសម្ពុទ្ធព្រះបរមគ្រូទ្រង់ប្រសូតចាកព្រះមាតុទរ ទ្រង់ត្រាស់ដឹងអនុត្តរសម្មាសម្ពោធិញ្ញាណ និងទ្រង់រំលត់ខន្ធចូលកាន់ព្រះបរមនិព្វាន។ ឯកសារដដែលក៏បានបង្ហាញដែរថា វិសាខបូជាប្រារព្ធឡើងដំបូងនៅប្រទេសឥណ្ឌា ហើយនៅកម្ពុជាបានផ្តួចផ្តើមក្នុងរជ្ជកាលព្រះបាទសម្តេចព្រះហរិរ័ក្ស (ព្រះអង្គដួង) ដែលគង់នៅក្រុងឧត្តុង្គឆ្នាំ១៨៥៤។[4] ក្នុងថ្ងៃពិសាខបូជានេះដែរ ជាទូទៅពុទ្ធសាសនិកតែងនាំគ្នាទៅកាន់ទីអារាមនានា ថ្វាយគ្រឿងបូជាផ្សេងៗ លំឱនការគោរពចំពោះគុណព្រះពុទ្ធអង្គដូចជា ទៀន ធូប ផ្កាភ្ញី និងប្រទីបផ្កាលាជាដើម។[5] វេលារាត្រី ពុទ្ធបរិស័ទជួបជុំនមស្ការសមាទានសីល និងជាពិសេសគឺស្តាប់ការសម្តែងធម្មទេសនាអំពីពុទ្ធប្រវត្តិ។ តាមគន្លងប្រពៃណី ការប្រារព្ធពិធីបុណ្យវិសាខបូជា មានការសម្តែងខ្សែរឿងពុទ្ធប្រវត្តិតាំងពីដើមដល់ចប់។ ការសម្តែងនោះ ជាគ្រឿងបណ្តុះសទ្ធាដល់ពុទ្ធបរិស័ទឱ្យកើតសេចក្តីជ្រះថ្លាក្នុងព្រះរតនត្រៃយ៍។[6]

ដោយឡែក បើក្រឡេកមើលគំនូរដែលតែងគូរតាមវត្ត បង្ហាញត្រង់ព្រះអង្គទ្រង់ប្រសូត ទ្រង់ត្រាស់ដឹង និងទ្រង់ចូលកាន់ព្រះបរមនិព្វាន ដែលកំណត់ជាហេតុនៃបុណ្យវិសាខបូជានោះ គេសង្កេតឃើញគំនូរទាំងបីអន្ទើមានលក្ខណៈសិល្បៈយ៉ាងល្អប្លែកគួរឱ្យពិចារណា។ គំនូរទ្រង់ប្រសូតនិងបរិព្វាន ច្រើនគូរនៅលើជញ្ជាំងព្រះវិហារ ដែលគេយល់ថាជាចំណុចចាប់ផ្តើម (ប្រសូត) និងបញ្ចប់សាច់រឿង (បរិនិព្វាន)។[7] អន្ទើទាំងពីរគេច្រើនគូរបញ្ចូលទិដ្ឋភាពពាក់ព័ន្ធនឹងសង្គមមនុស្សខ្មែរជាក់ស្តែងដូចជា នៅឧទ្យាន ឬប្រាសាទ

---

[4] ឈឹម ក្រសេម និងសហការី, ១៩៥១, ទំ.៥៧-៧៧

[5] ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ, ២០១៧, ទំ.១៨៣-១៨៤

[6] មាស សុភាព "ពិធីបុណ្យវិសាខបូជា" ផ្សាយលើតំណ https://ams.com.kh/khmercivilization/detail/7669 ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២១

[7] សាន ផល្លា, ២០០៧, ទំ.១៨-៣៩

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

បុរាណ មានព្រះឆាយាលក្ខណ៍ព្រះមហាក្សត្រខ្មែរ ឬថ្នាក់ដឹកនាំជាន់ខ្ពស់ ឬព្រះសង្ឃជាធំក្នុងវត្ត ឬរូបតួអង្គម្ចាស់សទ្ធាជាដើម។ ប៉ុន្តែសិល្បៈគំនូរនៅត្រង់ព្រះអង្គត្រាស់ដឹងច្រើនគូរនៅជ្រុងនិរតី ឬជញ្ជាំងខាងលិច ហើយមានអន្ទើពាក់ព័ន្ធក្បែរៗនោះដូចជា ទ្រង់ទទួលចង្ហាន់នាងសុជាតា និងទ្រង់ទទួលស្បូវភ្លាំងពីសោត្ថីយព្រាហ្មណ៍។

តាមពុទ្ធប្រវត្តិ ព្រះសម្មាសម្ពុទ្ធទ្រង់ប្រសូតនៅក្នុងឧទ្យានលុម្ពិនី ជាព្រំដែននៃនគរកបិលភស្តុនិងនគរទេវទហ ដែលមានឧទ្យានដើមឈើត្រឈឹងត្រឈៃ ផ្ការីកស្គុះស្គាយគួរជាទីមនោរម្យ។ សម័យថ្ងៃមួយ ព្រះនាងសិរិមហាមាយាដែលមានព្រះគភ៌គ្រប់ខែបានយាងឆ្លងកាត់ទៅសម្រាកព្រះកាយក្រោមដើមសាលព្រឹក្ស (រាំងប្រសូត) ហើយឈោងព្រះហស្តស្ដាំកាន់មែកសាលព្រឹក្ស (គំនូរវត្តខ្លះកាន់ទងផ្កា) (រូបលេខ២៣-៥)។ ភ្លាមនោះព្រះរាជកុមារក៏ប្រសូតចាកព្រះឧទរព្រះនាងសិរិមហាមាយា ហើយឈានពជំហាន មានផ្កាឈូកផុសទ្រព្រះបាទផង។

ចំពោះសិល្បៈគំនូរក្នុងទិដ្ឋភាពព្រះអង្គទ្រង់ប្រសូត ដែលជាហេតុទី១ នៃបុណ្យវិសាខបូជា តែងឃើញមានព្រះឥន្ទ្រ ព្រះព្រហ្ម និងទេពនិករផ្សេងៗយាងសាទរ។ សោតឯទិដ្ឋភាពមួយផ្នែកទៀត គំនូរវត្តខ្លះគេគូរព្រះភ័ក្ត្រអង្គក្សត្រដូចព្រះភ័ក្ត្រព្រះបាទបរមរតនកោដ្ឋក្នុងចំណោមមនុស្សម្នា និងបរិវារផងទាំងឡាយ ឬវត្តខ្លះគូរឧទ្យាននោះនៅខាងមុខប្រាសាទអង្គរ។


រូបលេខ២៣ គំនូរនៅព្រះវិហារវត្តអំពិល (បន្ទាយមានជ័យ)


រូបលេខ២៤ គំនូរនៅព្រះវិហារវត្តកណ្ដាល (កំពង់ចាម)


រូបលេខ២៥ គំនូរនៅវិហារវាំវិន្ទ (ភ្នំពេញ)

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ចំណែកសិល្បៈគំនូរគូរបង្ហាញត្រង់ព្រះអង្គត្រាស់ដឹង ជាហេតុទី២នៃបុណ្យវិសាខបូជា គេច្រើនគូរព្រះសម្មាសម្ពុទ្ធគង់សមាធិលើបល្ល័ង្កខ្ពស់មួយក្រោមដើមពោធិ។ គំនូរវត្តខ្លះគូរនាងសុជាតាថ្វាយចង្ហាន់ រួចហើយសោត្ថីយ៍ព្រាហ្មណ៍ថ្វាយស្បូវភ្លាំង ឬព្រះអង្គផ្សងភាជន៍មាសក៏រាប់ថាពាក់ព័ន្ធនឹងព្រះអង្គបានត្រាស់ ហើយគំនូរវត្តខ្លះទៀតគូរបង្ហាញអស់ទេវតាយាងចុះមកថ្វាយព្រះពរពេលព្រះអង្គបានត្រាស់។



រូបលេខ២៦ គំនូរព្រះវិហារវត្តកោះផ្ដៅ (កំពត)



រូបលេខ២៧ គំនូរព្រះវិហារវត្តទឹកជ្រៅ (ត្បូងឃ្មុំ)

អរិយធម៌ខ្មែរ KHMER CIVILIZATION

រីឯសិល្បៈគំនូរត្រង់ព្រះសម្មាសម្ពុទ្ធចូលព្រះនិព្វាននៅក្រុងកុសិនារា ជាហេតុទី៣នៃបុណ្យវិសាខបូជា គេគូរព្រះសម្មាសម្ពុទ្ធគង់ផ្ដេកព្រះកាយចន្លោះដើមសាលព្រឹក្សមួយគូមានផ្ការីកស្គុះស្គាយ។ ក្នុងពុទ្ធប្រវត្តិបញ្ជាក់ថា ព្រះអានន្ទរៀបចំឱ្យព្រះពុទ្ធអង្គទ្រង់គង់ដាក់ព្រះសិរទៅទិសខាងជើង ព្រះបាទទៅទិសខាងត្បូង ហើយក្នុងគំនូរតាមព្រះវិហារភាគច្រើនគូរលើជញ្ជាំងខាងកើត ព្រះសិរបែរទៅទិសខាងជើង ព្រះបាទទៅទិសខាងត្បូងដែរ។ ប៉ុន្តែក៏មានព្រះវិហារខ្លះ គូរព្រះសិរទៅទិសខាងត្បូង ព្រះបាទទៅទិសខាងជើង ឬគូរនៅលើជញ្ជាំងលិចក៏សឹងមាន (ករណីវត្តចុងដាច)។

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ក្នុងពុទ្ធប្រវត្តិរៀបរាប់ថា ពួកមល្លក្សត្រនិងអ្នកក្រុងកុសិនារា កើតទុក្ខយំសោកបោកខ្លួនស្តាយព្រះពុទ្ធអង្គជាពន់ពេកមកថ្វាយបង្គំព្រះសាស្តាក្នុងវេលាចុងក្រោយយ៉ាងច្រើនកុះករ។ ទិដ្ឋភាពត្រង់នេះ នៅតាមព្រះវិហារសម័យសង្គមរាស្ត្រនិយមខ្លះគេច្រើនគូរបញ្ចូលព្រះវត្តមានព្រះឆាយាលក្ខណ៍ព្រះមហាក្សត្រខ្មែរ[8] ជាពិសេសព្រះវត្តមាន ***ព្រះបរមរតនកោដ្ឋ*** និងរាជបរិវាមួយអន្ទើ ព្រមទាំងព្រះភិក្ខុសង្ឃមួយក្រុមគង់ខាងមុខសោកសៅស្តាយស្រណោះព្រះពុទ្ធអង្គ។ ប៉ុន្តែក្នុងចំណោមនោះមានព្រះភិក្ខុមួយព្រះអង្គគង់សមាធិដោយស្ងៀមស្ងាត់។ ក្នុងគំនូរព្រះវិហារវត្តពុទ្ធា គេគូរទិដ្ឋភាពព្រះពុទ្ធបរិនិព្វាននៅឧទ្យាន មុខប្រាសាទអង្គរវត្ត ហើយគូរព្រះឆាយាលក្ខណ៍ ***ព្រះបាទ នរោត្តម សុរាម្រឹត*** និង ***ព្រះមហាក្សត្រីយានី*** ព្រមទាំង ***ព្រះបរមរតនកោដ្ឋ*** គង់នៅក្រោយព្រះសពព្រះសម្មាសម្ពុទ្ធ។ ព្រះឆាយាលក្ខណ៍ ***ព្រះបរមរតនកោដ្ឋ*** គេគូរជាពីរអង្គ ពោលគឺមួយបែបទ្រង់អាវធំរបៀបផ្លូវការបែបអឺរ៉ុប និងមួយទៀតទ្រង់ព្រះភូសាកុតកពណ៌ស។



*រូបលេខ២៨ គំនូរព្រះវិហារវត្តពុទ្ធា (ត្បូងឃ្មុំ)*

ជារួមមក វិសាខបូជាជាបុណ្យដ៏មានសារៈសំខាន់បំផុតក្នុងព្រះពុទ្ធសាសនា ដើម្បីរំលឹកដល់ថ្ងៃព្រះពុទ្ធទ្រង់ប្រសូត ត្រាស់ដឹង និងបរិនិព្វាន ដែលអង្គការសហប្រជាជាតិទទួលស្គាល់ជាអន្តរជាតិ និងត្រូវបានរាជរដ្ឋាភិបាលកម្ពុជា កំណត់ជាថ្ងៃបុណ្យជាតិជា

[8] ព្រាប ចាន់ម៉ារ៉ា, ២០២២

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

រៀងរាល់ឆ្នាំ។ ទន្ទឹមនឹងការប្រារព្ធពិធីសាសនាតាមវត្ត គេអាចសន្និដ្ឋានបានថាសិល្បៈគំនូរតាមព្រះវិហារបង្ហាញពីពុទ្ធប្រវត្តិទាំងបីអន្លើ បានឆ្លុះបញ្ចាំងពីការវិវត្តនៃសិល្បៈខ្មែរ ដោយបានបញ្ចូលនូវតថភាពសង្គមជាក់ស្តែងដូចជា រូបប្រាសាទបុរាណ ឧទ្យាន និងព្រះឆាយាលក្ខណ៍ព្រះមហាក្សត្រទៅក្នុងសាច់រឿង។ ការបញ្ច្រាបអត្តសញ្ញាណជាតិទៅក្នុងសិល្បៈពុទ្ធសាសនាបែបនេះ មិនត្រឹមតែជួយបណ្តុះសទ្ធាជ្រះថ្លាដល់ពុទ្ធបរិស័ទប៉ុណ្ណោះទេ ថែមទាំងជាភស្តុតាងប្រវត្តិសាស្ត្រដ៏មានតម្លៃ ដែលបង្ហាញពីការផ្សារភ្ជាប់គ្នាយ៉ាងស្អិតរមួតរវាងសាសនា ព្រះមហាក្សត្រ និងវប្បធម៌ខ្មែរតាំងពីបុរាណរហូតមកដល់បច្ចុប្បន្ន។

## ឯកសារយោង


អគ្គនាយកដ្ឋានបច្ចេកទេសវប្បធម៌

២០១៧, *បញ្ជីសារពើភណ្ឌបេតិកភណ្ឌវប្បធម៌អរូបីកម្ពុជា*, ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ, ភ្នំពេញ

ថង វង

១៩៦២, "ពិធីបុណ្យវិសាខបូជានៅមុខព្រះសក្យមុនីចេតិយ", *កម្ពុជសុរិយា*, លេខ៥, ឆ្នាំទី៣៤, ទំ.៥៩២-៥៩៨, ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ

ឈឹម ក្រសេម និងសហការី,

១៩៥១, *ព្រះរាជពិធីទ្វាទសមាស*, ភាគ២, ទំ.៥៧-៧៧, ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ

ព្រាប ចាន់ម៉ារ៉ា

២០២២, *ព្រះបរមរតនកោដ្ឋក្នុងគំនូរនៅតាមវត្ត*, សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ, ភ្នំពេញ

មាស សុភាព

២០២១, "ពិធីបុណ្យវិសាខបូជា" ផ្សាយលើតំណ https://ams.com.kh/khmer civilization/detail/7669 ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២១

សាន ផល្លា

២០០៧, *គំនូរនៅតាមវត្ត*, រ៉ៃយំ, ភ្នំពេញ


អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

AMS អរិយធម៌ខ្មែរ KHMER CIVILIZATION